**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សូមក្រាបបង្គំទូលថ្វាយ

## សម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស
## សម្ដេចព្រះមហាសង្ឃរាជនៃគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា

ខណៈនេះទូលព្រះបង្គំខ្ញុំព្រះករុណានិងភរិយា មានក្ដីក្ដុកក្ដួល ខ្សឹកខ្សួល ជាអនេកប្បការ ដោយបានទទួលដំណឹងថា សម្ដេចព្រះធម្មលិខិតកិត្តិបណ្ឌិត **លាស់ ឡាយ** សម្ដេចព្រះសង្ឃនាយករងទី១ និងជាព្រះចៅអធិការវត្តសន្សំកុសល ទទួលព្រះអនិច្ចធម្ម នៅថ្ងៃអង្គារ ០២ កើត ខែកត្ដិក ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១៩ ក្នុងព្រះជន្ម ១០៦ ព្រះវស្សា ដោយព្រះជរាពាធ ។

ក្នុងឱកាសប្រកបដោយសមានទុក្ខដ៏មហាក្រៀមក្រំនេះ ទូលព្រះបង្គំខ្ញុំព្រះករុណានិងភរិយា មានក្ដីសង្វេគ សោកស្ដាយ ស្រណោះ អាឡោះអាល័យស្ទើររកទីបំផុតគ្មាន ព្រោះថាការទទួលព្រះអនិច្ចធម្មរបស់សម្ដេចព្រះធម្មលិខិត **លាស់ ឡាយ** គឺជាការបាត់បង់សមាណសង្ឃជាពហុស្សូតដ៏ឆ្នើមបំផុត ក្នុងការលើកស្ទួយតម្កើងព្រះពុទ្ធសាសនា និងជាព្រះករុណាទិពទ្ធពោរពេញដោយព្រះពុទ្ធិជ្រៅជ្រះ ពិសេសសម្ដេចធម្មលិខិត **លាស់ ឡាយ** បានបន្សល់នូវស្នាព្រហស្ដច្រើនឥតគណនាក្នុងវិស័យពុទ្ធចក្រ អាណាចក្រ និងរួមចំណែកព្រះបរិច្ចាគ ទ្រទ្រង់ចលនាមនុស្សធម៌កាកបាទក្រហមកម្ពុជា ដោយព្រះសទ្ធាជ្រះថ្លាបរិសុទ្ធទៀតផង។

ជាថ្មីម្ដងទៀត ទូលព្រះបង្គំខ្ញុំព្រះករុណានិងភរិយា សូមឧទ្ទិសដល់ដួងព្រះវិញ្ញាណក្ខន្ធ សម្ដេចព្រះធម្មលិខិត **លាស់ ឡាយ** សូមយាងនិមន្តសោយសុខក្នុងសុគតិភពកុំបីឃ្លាតឃ្លាយទៅជាបការៈដទៃឡើយ ។

សូម **សម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស** ទទួលនូវអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់ពីទូលព្រះបង្គំខ្ញុំព្រះករុណានិងភរិយា។

*ថ្ងៃ អង្គារ ០២ កើត ខែ កត្ដិក ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣*

*រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១៩*

**ហ៊ុន សែន**